**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោក BERNAD JASPERS FAIJER នាយកអង្គការ ZOA ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានជួយកសាងអាគារសិក្សា១ខ្នង នៅសាលាបឋមសិក្សា កាត់ភ្លុក ក្នុងឃុំព្រះខែ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ចំណាយអស់ទឹកប្រាក់ចំនួន ២២.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តនីអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០០

**សេចក្ដីសំរេច ០៩ សសរ**

**ស្ដីពី ការបង្កើតក្រុមការងារ កិច្ចការបច្ចេកទេស**

**ដើម្បីធ្វើការងារផ្ទាល់ជាមួយក្រុមហ៊ុន DUHACO**

**របស់វៀតណាម**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រមលេខ នស/រកម//០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង រៀបចំដែនដី នគរូបនីយកម្មនិងសំណង់

-តាមសំណើរបស់ក្រសួង រៀបចំដែនដី នគរូបនីយកម្មនិងសំណង់

## សម្រេច

ប្រការ ១ : បង្កើតក្រុមការងារកិច្ចបច្ចេកទេស ដើម្បីធ្វើការដោះដូរជាមួយក្រុមហ៊ុន DUHACO របស់វៀតណាម ដែលរួមមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១-លោក ស៊ៃ សុខមុត | តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២-លោក ឡុង សុភ័ក្ត | តំណាង ក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣-លោក សុះ ភារ | តំណាង ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤-លោក ឌុច សុភ័ត | តំណាង ក្រសួង បរិស្ថាន | សមាជិក |
| ៥-លោក ស៊ឹម គីមស្រ៊ឹម | តំណាង ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក ឡុង ពៅក្រាញ់ | តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧-លោក ឆាយ វ៉ាន់ឆន | តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-លោក ម៉ាន់ សុផាត | តំណាង អភិបាលខេត្តក្រចេះ | សមាជិក |
| ៩-មន្ត្រីរបស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | លេខាធិការ |

ប្រការ ២ : ក្រុមការងារនេះមានភារកិច្ច :

ត្រូវធ្វើការចរចារ ពិភាក្សាអំពីលទ្ធភាព សមត្ថភាពទុន សញ្ញាណលក្ខណៈបច្ចេកទេស និងបទពិសោធន៍ការងាររបស់ក្រុមហ៊ុន ដែលធ្លាប់បានធ្វើកន្លងមក ព្រមទាំងចរចាអំពីលក្ខខណ្ឌការងារផ្សេងៗ ទៀតជាមួយក្រុមហ៊ុន ។

ប្រការ៣ : ក្រុមការងារនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ។

ប្រការ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលខេត្តក្រចេះ និងអស់លោក ដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★